ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៩៦៧ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០១

# ប្រកាស

## ស្តីពី

## វិធានការគ្រប់គ្រងនិដ្ឋាការស្ថិត

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញ ព្រះរាជក្រមលេខ ០១.នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និង ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ១៩៩៩

-បានឃើញ អនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ

-បានឃើញ អនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

-បានឃើញ សារាចររបស់រាជរដ្ឋាភិបាលលេខ ០៦.សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការកែទំរង់ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

-បានឃើញប្រកាសស្តីពីការប្រមូលចំណូលទិដ្ឋាការលេខ ៣០៤ សហវ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១

-បានឃើញចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០១ លើលិខិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ៥៤១៨ សហវ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០១

-យោងស្មារតីនៃការប្រជុំអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ធនាគារជាតិនៃកម្ពុជា ស្តីពីបញ្ហាអនុវត្តទិដ្ឋាការស្ទិត នាថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០១

-តាមការចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីទិដ្ឋាការ

-យោងប្រកាសស្តីពីវិធានការគ្រប់គ្រងទិដ្ឋាការស្ទិត លេខ៨៦១ សហវ.ថហ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១

-តាមការចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីទិដ្ឋាការ

## សំរេច

**ប្រការ១:** ត្រូវបានកែប្រែប្រការ២នៃប្រកាស លេខ៨៦១ សហវ.ថហ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ មានខ្លឹមសារដូចខាងក្រោម :

**ប្រការ២ថ្មី:** សន្លឹកទិដ្ឋាការស្ទិតមានពីរប្រភេទគឺ ប្រភេទទី១ :មានផ្ទៃពណ៌បៃតងស្រស់ សំរាប់ផ្តល់អោយជនបរទេស ធ្វើដំណើរ ចូលមកប្រទេសកម្ពុជា និង ប្រភេទទី២ : មានផ្ទៃពណ៌ខៀវថ្លា ដែលមានអក្សរ EX នៅក្នុងផ្ទៃសំរាប់ពន្យា ទិដ្ឋាការការស្នាក់នៅក្នុងប្រទេសកម្ពុជា ។

**ប្រការ២:** ប្រការ២ចាស់នៃប្រកាស លេខ៨៦១ សហវ.ថហ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៣</u>: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្មនិងហិរញ្ញកិច្ច ប្រធានរតនាគារជាតិ ប្រធា អង្គភាពគ្រប់គ្រងរូបិយបណ្ណ័ ព្រមទាំង ប្រធានអង្គភាពពាក់ពន្ធ័ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណុះក្រសួងកា បរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ និងចំណុះធនាគារជាតិនៃកម្ពុជាត្រូវទទួលបន្ទុកអនុវ ប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជាពត៌មាន "
- ក្រសួងមហាផ្ទៃ " ដើម្បីសុំសហការក្នុងការអនុវត្តន៍ "
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ " ដើម្បីសុំសហការក្នុងការអនុវត្តន៍ "
- ធនាគារជាតិនៃកម្ពុជា" ដើម្បីសូមសហការក្នុងការអនុវត្តន៍ "
- ឯកសារ និង កាលប្បវត្តិ